**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

លេខ:០០៧ /០៨ កហ អ.គ.គ

## កំណត់ហេតុ កិច្ចប្រជុំ ក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

ឆ្នាំពីពាន់ប្រាំបី ខែ មេសា ថ្ងៃទី ប្រាំពីរ វេលាម៉ោងដប់បួន និងសាមសិបនាទី នៅសាលប្រជុំ C15 នៃទីស្តី ការគណៈរដ្ឋមន្រ្តី (អតីតរដ្ឋសភាចាស់) មានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពរបស់ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពិនិត្យ និងពិភាក្សាបន្តលើកិច្ចការរបស់ក្រុមការងារបច្ចេកទេស ចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម សំ សុខផល បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍មួយចំនួន និងមន្រ្តីអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញចូលរួមប្រជុំក្រុមការងារ បច្ចេកទេសលើកទី២ក្នុងថ្ងៃនោះ ។ ជាបន្ទាប់ឯកឧត្តមបានមានប្រសាសន៍ថា កិច្ចប្រជុំថ្ងៃនេះ គឺដើម្បីពិនិត្យមើល និងតាមដានជាបន្តទៅលើសូចនាករតាមដានរួម ( JMI ) និងពិភាក្សាលើសូចនាករតាមដានរួមថ្មីមួយ ទៀត ( New JMI ) ដែលពាក់ព័ន្ធដល់កំណែទម្រង់ច្បាប់ និងតុលាការ ។

ក្នុងពេលនោះ ឯកឧត្តមបានធ្វើរបាយការណ៍សង្ខេបស្តីពីស្ថានភាពច្បាប់ទាំងប្រាំបី ប៉ុន្តែឯកឧត្តមបាន លើកយកច្បាប់ទាំង៤មកបរិយាយក្នុងចំណោមច្បាប់ទាំងប្រាំបីនោះ ដែលជាសូចនាករតាមដានរួម គឺ ៖

១- ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុម័តរួចហើយ

២- ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័តហើយ

៣- ក្រមរដ្ឋប្បវេណី ត្រូវបានសភាអនុម័តហើយ ប៉ុន្តែមិនទាន់បានអនុវត្តនៅឡើយទេ គឺកំពុងតែធ្វើការ ផ្សព្វផ្សាយ

៤- សេចក្តីព្រាងក្រមព្រហ្មទណ្ឌកំពុងត្រូវបានធ្វើការពិនិត្យជាចុងក្រោយ ដោយក្រុមការងារបច្ចេកទេសមួយក្រុម របស់ក្រុមប្រឹក្សាអ្នកច្បាប់ មុនពេលដាក់ជូនទៅអន្តរក្រសួង ។

ចំណែកច្បាប់ផ្សេងៗទៀតទាក់ទងនឹងវិស័យតុលាការ គឺនៅក្នុងស្ថានភាពដដែល ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមប្រធាន បានស្នើសុំអង្គប្រជុំលើកយោបល់ជុំវិញស្ថានភាពច្បាប់ទាំង ប្រាំបីនោះផងដែរ ។

យោងតាមរបៀបវារៈចំណុចទី៣ ស្តីពីរបាយការណ៍សកម្មភាពរបស់អនុក្រុមនីមួយៗ ឯកឧត្តម ប្រធានបានមានប្រសាសន៍ថា អនុក្រុមទី១ និងអនុក្រុមទី៤ បានធ្វើការរាយការណ៍ស្តីពីភាពជឿនលឿន នៃសកម្មភាពរបស់អនុក្រុមទាំងពីរកាលពីកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះលើកទី១ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈឆ្នាំ២០០៨ រួចមកហើយ ដូច្នេះ ឯកឧត្តមបានស្នើសុំអោយអនុក្រុមទី៤ ធ្វើសេចក្តី រាយការណ៍ ជូនអង្គប្រជុំ ទាំងមូល ។

លោក Rajan Shah (Access to Justice Advisor) EWMI តំណាងអនុក្រុមទី៤ បានមានប្រសាសន៍ ថាអនុក្រុមរបស់លោក បានពិនិត្យទៅលើយុទ្ធសាស្រ្តទី៤ និងយុទ្ធសាស្រ្តទី៥ដែលមានសកម្មភាពចំនួនបី គឺ ៖

1- សកម្មភាពការអប់រំ សម្រាប់ផ្នែកវិជ្ជាជីវៈច្បាប់

2- តុលាការគំរូ

3- ជំនួយផ្នែកច្បាប់

មិនតែប៉ុណ្ណោះលោកបានជម្រាបថា អនុក្រុមរបស់លោកបានអញ្ជើញភ្ញៀវជាវាគ្មិន ដើម្បីពិភាក្សា នៅលើសកម្មភាពនីមួយៗដែលបង្ហាញខាងលើនេះស្រាប់ ហើយលោកបានបញ្ជាក់ទៀតថា កិច្ចប្រជុំ លើកទី១ អនុក្រុមទី៤នេះ បានលើកយកសកម្មភាពជំនួយផ្នែកច្បាប់មកពិភាក្សា ដោយមានខាងក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាអ្នកអញ្ជើញអង្គការផ្សេងៗ ដូចជាអង្គការជាតិ អន្តរជាតិ ដែលពាក់ព័ន្ធវិស័យ ផ្នែកច្បាប់ និងបូករួមទាំងគណៈមេធាវីផងដែរ នេះជាការចែករំលែកនូវបទពិសោធន៍ និងជាអនុសាសន៍ខ្លះៗ ដើម្បីអោយវិស័យផ្នែកច្បាប់កាន់តែមានភាពល្អប្រសើរ ឡើងថែមទៀតនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាបន្ទាប់ លោកបានលើកឡើងពីរបាយការណ៍របស់អនុក្រុមទី៤ នៃក្រុមការងារបច្ចេកទេស កាលពីកិច្ចប្រជុំនៅខែកុម្ភៈ ដែលពិភាក្សាចំៗអំពីផ្តល់ជំនួយផ្នែកច្បាប់ ( របាយការណ៍នេះបានចែកជូនអង្គ ប្រជុំរួចជាស្រេចហើយ )។ ចំណុច ដែលត្រូវពិភាក្សាគឺ ៖

<u>ការតាមដានស្ទង់មតិជំនួយផ្នែកច្បាប់កាលពីឆ្នាំ ២០០៦</u>

នៅឆ្នាំ ២០០៦ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានការឧបត្ថម្ភគាំទ្រ ពីកម្មវិធីសិទ្ធិ និងយុត្តិធម៌ដែលផ្តល់មូលនិធិដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ហើយអនុវត្តដោយ វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម បានទទួលធ្វើការស្ទង់មតិថ្នាក់ជាតិមួយ ដែលនាំ អោយមានការបោះពុម្ពផ្សាយរបាយការណ៍នៅខែធ្នូ ឆ្នាំ ២០០៦ ត្រូវបានដាក់ឈ្មោះថា " ជំនួយផ្នែក ច្បាប់នៅប្រទេសកម្ពុជា ៖ ការអនុវត្តការ យល់ដឹង និងតម្រូវការ " ។

ការស្ទង់មតិត្រូវបានកំណត់បញ្ហាបួនសំខាន់ៗ ឬភាពមិនគ្រប់គ្រាន់ទាក់ទងទៅនឹងជំនួយផ្នែក ច្បាប់នៅប្រទេសកម្ពុជា និងការផ្តល់របស់ខ្លួន ។ ការពាក់ព័ន្ធទាំងនេះរួមមាន ៖ ១-ថវិកា និងហិរញ្ញវត្ថុ ២-គ្រឹះស្ថានអប់រំ និងហេដ្ឋារចនា សម្ព័ន្ធ ៣-បុគ្គលិក និងធនធានមនុស្ស ៤-ការយល់ដឹងក្នុងចំណោម កូនក្តីដែលបានផ្តល់ ។ អនុសាសន៍ទាំងឡាយមានសារប្រយោជន៍ ដោយចាត់ទុកជាផ្នែកនៃដំណោះ

ស្រាយរួមគ្នាដើម្បីធ្វើអោយល្អ ប្រសើរដល់ការផ្តល់ជំនួយផ្នែកច្បាប់ ដែលមាន រយៈពេលខ្លី មធ្យម និងរយៈពេលវែង ។

ក្នុងកំឡុងឆ្នាំមុន ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងក្រសួងយុត្តិធម៌ សហការជាមួយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ និងវិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម បានអនុវត្តសកម្មភាព ជាច្រើនឆ្លើយតបទៅនឹងអនុសាសន៍ ។

1. បង្កើនការយល់ដឹងក្នុងចំណោមកូនក្តីដែលទទួលជំនួយផ្នែកច្បាប់

**ក. វិទ្យុ និង កម្មវិធីផ្តល់ប្រឹក្សា**

- ចំនួន ២០ ឈុតកម្មវិធីចាក់ផ្សាយតាមវិទ្យុ ដោយវិទ្យុផ្កាយរណប និងស្ថានីយ៍ FM ទូទាំងប្រទេស កម្ពុជា
- ការប្រកាសជូនដំណឹងអំពីសេវាកម្មសាធារណៈ
- ការបណ្តុះបណ្តាល និងការផ្តល់ប្រឹក្សា

**ខ. សៀវភៅមគ្គុទ្ទេសក៍ សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់**

- តារាងបញ្ជីថ្នាក់ជាតិនៃករផ្តល់សេវាកម្មមានទូទាំងប្រទេស
- បានចែកជូនតាមតុលាការ ឃុំ/សង្កាត់ អង្គការមិនមែនរដ្ឋាភិបាល ក្រសួងកិច្ចការនារី និងក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ល។

**គ. ក្តារប្រកាសព័ត៌មានជាសាធារណៈនៅគ្រប់តុលាការទាំងអស់**

- តារាងក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍ អន្តរជាតិ/វិទ្យា-ស្ថាន គ្រប់គ្រងបូព៌ា-បច្ចឹម បានរៀបចំនិងតម្លើងបីផ្នែកខុសៗគ្នាពីក្តារ ព័ត៌មានសម្រាប់សាធារណជន។ ផ្នែកទី១សង្ខេបតម្លៃសម្រាប់ថ្លៃដាក់ពាក្យបណ្តឹងវិវាទរដ្ឋប្បវេណី និងសង្ខេបលក្ខណៈ វិនិច្ឆ័យ៍នៃការលើកលែងប្រាក់ប្រដាប់ក្តីសម្រាប់ដើមបណ្តឹងដែលក្រីក្រ។ ផ្នែកទី២ សង្ខេបសិទ្ធិរបស់គូវិវាទ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសអោយប្រើនៅពេលថ្មីៗ ។ ផ្នែកទី៣ ផ្តល់ព័ត៌មានអំពីសិទ្ធិរបស់ជនជាប់ចោទអនីតិជន និងជនរងគ្រោះដោយ ឧក្រិដ្ឋកម្ម ដែលយោងតាមច្បាប់នីតិវិធីព្រហ្មទណ្ឌថ្មី ។

2. ការពង្រីកសេវាកម្មជំនួយផ្នែកច្បាប់

- នៅតុលាការគំរូខេត្តកណ្តាល ក្រសួងយុត្តិធម៌ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍ អន្តរជាតិ/វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បច្ចឹម និងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា បានបង្កើតកម្មវិធីអ្នកការពារសាធារណៈជន ។
- កម្មវិធីត្រូវបានរៀបចំធ្វើអោយប្រាកដថា ចុងចោទនៃករណីព្រហ្មទណ្ឌដែលក្រីក្រ ( ជាពិសេសកុមារ ) មានសិទ្ធិទទួលបានប្រឹក្សា និងតំណាងយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន ។
- ក្នុងរយៈពេល៦ខែដំបូង ជនជាប់ចោទជាង ២០០ នាក់បានទទួលមេធាវី

3. ភាពអាចរកបាននូវធនធានផ្នែកច្បាប់

- បណ្ណាល័យផ្នែកច្បាប់សាកល្បងត្រូវបានបង្កើតឡើងនៅតុលាការគំរូខេត្តកណ្តាល ដោយផ្តល់ជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ/ វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បច្ចឹម ។ គម្រោង នេះរួមទាំងបណ្ណារក្សតុលាការដែលបណ្តុះ-បណ្តាលលើកទី១ ។

4. ការសម្របសម្រួល

- សង្ឃឹមថា អនុក្រុមទី៤នៃក្រុមការងារបច្ចេក នឹងជួយក្នុងការសម្រប សម្រួលអោយបានប្រសើរ រវាងរដ្ឋាភិបាលដៃគូម្ចាស់ជំនួយ និងសង្គមស៊ីវិល ។

<u>**អនុសាសន៍បន្ថែម**</u>

ក្នុងការពិភាក្សាអ្នកផ្តល់សេវកម្មជំនួយផ្នែកច្បាប់បានសង្ខេបបទពិសោធន៍របស់ខ្លួននៅតុលាការ ហើយបានផ្តល់យោបល់ជាអនុសាសន៍ ដូចជា ៖

<u>**ហេដ្ឋរចនាសម្ព័ន្ធពន្ធនាគារ**</u>

1- មានទូរស័ព្ទសម្រាប់អ្នកដែលនៅក្នុងឃុំបណ្តោះអាសន្នមុនពេលជម្រះ ដើម្បីអោយពួកគាត់អាចទំនាក់ទំនង ទៅទីប្រឹក្សារបស់ខ្លួន ឬអាចរៀបចំសម្រាប់ការផ្តល់ ប្រឹក្សា ។

2- បន្ទប់ធ្វើសម្ភាសន៍កូនក្តីនៅក្នុងពន្ធនាគារ ។

<u>**ហេដ្ឋរចនាសម្ព័ន្ធ និងនីតិវិធីតុលាការ**</u>

១- ការបណ្តុះបណ្តាលបន្ទប់មេធាវីនៅតុលាការ(ប្រហាក់ប្រហែល គ្នាទៅនឹងតុលាការគំរូខេត្តកណ្តាល)

២- បំបែកតុលាការកុមារ និងការចុះបញ្ជី

៣- ការកែបញ្ជាក់អោយច្បាស់នូវច្បាប់ស្តីពី រយៈពេលអតិបរមាសម្រាប់សវនាការលើករណី ដែលប្តឹងឧទ្ធរណ៍ ។

តំណាង JICA បានលើកយកចំណុចអនុសាសន៍ចុងក្រោយ ដែលសុំអោយមានរយៈពេលឧទ្ធរណ៍ចំពោះ រឿងរដ្ឋប្បវេណីអោយបានច្បាស់លាស់ ព្រោះនេះជាចំណុចសំខាន់ណាស់ ព្រោះនៅពេលចុះធ្វើការផ្សព្វផ្សាយ ច្បាប់ជាមួយ ក្រសួងយុត្តិធម៌នៅតុលាការខេត្តស្វាយរៀង យើងបានពិភាក្សាលើក្រមនីតិវិធីរដ្ឋប្បវេណីចាស់ ដោយនៅក្នុងក្រមនេះ ពេលប្តឹងឧទ្ធរណ៍មានរយៈពេល២ខែ ប៉ុន្តែច្បាប់ថ្មីមានរយៈពេលតែ១ខែទេ ហេតុនេះ សអោយយើងឃើញថាយើងមាន ក្រមនីតិវិធីរដ្ឋប្បវេណីបញ្ជាក់ច្បាស់លាស់ហើយ ។

លោកជំទាវ សម មូនីកា អគ្គនាយករងនៃក្រសួងកិច្ច ទាក់ទងនឹងរបាយការណ៍របស់ EWMI លោកជំទាវ មានសំណួរសួរថា ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ ថាតើការដាក់ទូរស័ព្ទនេះ សម្រាប់អោយ ជនជាប់ចោទធ្វើការទំនាក់ទំនងប្រើប្រាស់ ឬសម្រាប់អាជ្ញាធរមានសមត្ថកិច្ច ? លោកជំទាវ បានមានមតិថា មិនឃើញមានអនុសាសន៍ណាមួយ ច្បាស់លាស់ទេរយៈពេលប្តឹងឧទ្ធរណ៍ នៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌនោះ ។

លោក Rajan Shah បានឆ្លើយបញ្ជាក់ថា អាចប្រើប្រាស់បានទាំងពីរបុគ្គល គឺទាំងជនជាប់ចោទ និងសម្រាប់អាជ្ញាធរមានសមត្ថកិច្ចផងដែរ ប៉ុន្តែអ្វីដែលគួរអោយបារម្ភនោះ គឺយើងមិនដឹងថា ការ ប្រើប្រាស់បណ្តាញ ទូរស័ព្ទនេះមានសុវត្ថិភាព ឬយ៉ាងណានោះទេ ។ ចំពោះរយៈពេលនៃការប្តឹងឧទ្ធរណ៍ លោកបានបញ្ជាក់ថា ក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់រយៈពេលប្តឹងឧទ្ធរណ៍ គឺមានរយៈពេល១ខែ ចំណែក ក្រមនីតិវិធីព្រហ្មទណ្ឌ លោកបានមានប្រសាសន៍ដែរថា បើមានពេលសម្រាប់រយៈពេលប្តឹងឧទ្ធរណ៍ ចំនួន១ខែ ក៏សមល្មមដែរ ។

លោកជំទាវ សម មូនីកា បានស្នើសុំអោយអនុក្រុមទី៨ដាក់ចេញជាអនុសាសន៍ មួយអោយបាន ច្បាស់លាស់ ក្នុងការកំណត់រយៈពេលនៃការប្តឹងឧទ្ធរណ៍ ប៉ុន្តែលោក Rajan Shah បានឆ្លើយតបថា មិនទាន់អាចសម្រេចបានទេ លុះត្រាតែលោកពិនិត្យមើលឃើញថា រយៈប៉ុន្មានទើបសមស្រប ហើយនឹង ចាំស្វែងយល់ពី ប្រទេសផ្សេងៗដែលគេគោរពច្បាប់បានល្អ មកធ្វើជាគំរូជាមុនសិន រួចយើងនឹងពិភាក្សា លើបញ្ហានេះម្តងទៀត។

ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង បានមានប្រសាសន៍ដូចជាខាង (EWMI ) ដែរ ។

លោក លី តៃសេង អគ្គលេខាធិការគណៈមេធាវីកម្ពុជា បានលើកឡើងថា ទាក់ទិននឹង Legal Aid នេះ សំខាន់ណាស់ ខាងគណៈមេធាវីព្យាយាមរកមធ្យោបាយ និងផ្តល់សេវានេះអោយបាននៅជិតបំផុត ដោយ លោកបានបញ្ជាក់ថា សេវានេះមានទំហំធំ ទាំងរឿងក្តីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ក្នុងពេលនោះដែរ លោក បានស្នើសុំអោយខាងដៃគូអភិវឌ្ឍន៍ និងប្រទេសអ្នកផ្តល់ជំនួយ ជួយដល់ចំណុចណាមួយបានក្នុង ចំណោមរឿងក្តីកុមារ រឿងវិវាទដីធ្លី និង Gender ជាដើម ។ល។

លោកជំទាវ សម មូនីកា បានជម្រាបថា ចំពោះសេវាមេធាវីសម្រាប់ជនក្រីក្រថា លុះត្រាតែ មានការបញ្ជាក់ពីមេឃុំថា បុគ្គលនោះពិតប្រាកដជាក្រីក្រមែន ទើបមានសេវាមេធាវីជួយការពារក្តីបាន តែបើគ្មានការ បញ្ជាក់ច្បាស់លាស់ពីមេឃុំទេនោះ មិនអាចមានសេវានេះឡើយ ហេតុដូចនេះលោក ជំទាវបានស្នើសុំអោយ ខាងគណៈមេធាវីជួយសម្រួលកិច្ចការនេះ ដោយមិនចាំបាច់បញ្ជាក់ពីមេឃុំ ។

ជាបន្ទាប់លោកជំទាវបានលើក ឡើងពីបញ្ហាមេធាវីនៅតាមអង្គការក្រៅរដ្ឋាភិបាលថា មានមេធាវីខ្លះទាមទារប្រាក់ពីជនក្រីក្ររហូតដល់ ៥០០ដុល្លារ ថែមទៀតផង ។

លោក លី តៃសេង បានឆ្លើយតបទៅនឹងលោកជំទាវថា ការធ្វើលិខិតបញ្ជាក់ពីមេឃុំនេះ ចាំបាច់តម្រូវអោយមានបែបបទនេះ ដើម្បីបំពេញបែបបទនៃការចាយវាយថវិកា ។ លោកបានអះអាងថា ចំពោះមេធាវីការពារក្តីជនក្រី ក្រនេះអង្គការមិនមានគោលការណ៍អោយមេធាវីយកលុយពីជនក្រីក្រនោះទេ ដូច្នេះលោក បានជម្រាបផងដែរថា ប្រសិនបើលោកជំទាវមានព័ត៌មានទាក់ទង នឹងការទាមទារប្រាក់ឈ្នួលនេះ សូមជួយផ្តល់ជាព័ត៌មានមកខាងគណៈមេធាវីផង ដើម្បីចាត់ការរឿងនេះ ប៉ុន្តែយើងមានការពិបាកដោះស្រាយគឺ ដោយសារគ្មានភ័ស្តុតាងបញ្ជាក់ពីការទារប្រាក់ពីកូនក្តី ដែលជាជនក្រីក្រនោះ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានឯកភាពទៅលើអនុសាសន៍ខាងលើ ហើយឆ្លៀតឱកាសនោះដែរ ឯកឧត្តមបានអំពាវនាវដល់ប្រទេសអ្នកផ្តល់ជំនួយទាំងឡាយ គណៈមេធាវី និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដែលផ្តល់សេវាជំនួយផ្នែកច្បាប់នេះ តាមរយៈការរៀបចំការប្រជុំដើម្បីពិភាក្សាបញ្ហាលំអិតច្រើនថែមទៀត ព្រោះជាបញ្ហាដ៏ធ្ងន់ធ្ងរមួយដែលមានឥទ្ធិពលប៉ះពាល់ដល់រាជរដ្ឋាភិបាល ដូចជាករណីសេវាមេធាវីការពារក្តីជូនប្រជាពលរដ្ឋក្រីក្រទារប្រាក់ពីកូនក្តីនេះជាដើម ។

ឯកឧត្តម សំ សុខផល បានបញ្ជាក់ថា ចំពោះសេវាជំនួយផ្នែកច្បាប់ និងសេវាការពារក្តីជូនប្រជាពលរដ្ឋក្រីក្រនេះ ទុកជូនឯកឧត្តម ស៊ុយ ម៉ុងលាង និង លោក លី តៃសេង ជាអ្នកធ្វើការពិភាក្សាតទៅទៀត ។ ហើយជាបន្ទាប់ ឯកឧត្តមប្រធានបានបន្តកិច្ចប្រជុំតាម របៀបវារៈស្តីពីការពិភាក្សាសូចនាករតាមដានរួមថ្មី ដោយ ស្នើសុំអោយខាងដៃគូអភិវឌ្ឍន៍លើកឡើងនូវ សូចនាករតាមដានរួមថ្មីនេះ សម្រាប់ការប្រជុំ CDCF នៅចុងឆ្នាំ នេះ ។

លោកស្រី Kate, AusAid បានមានប្រសាសន៍ថា ទាក់ទងទៅនឹងសូចនាករតាមដានរួមថ្មីនេះ គឺត្រូវបន្ថែមពីលើការធ្វើសេចក្តីព្រាងច្បាប់ជាមូលដ្ឋាន ដែលបានកំណត់ និងមានការដាក់បន្ថែមទាំងការត្រួតពិនិត្យ នូវការអនុវត្តនូវច្បាប់ជាមូលដ្ឋានទាំងនោះ ៖

- ច្បាប់ដែលបំរុងនឹងដាក់ក្នុងសូចនាករតាមដានរួមថ្មីនោះ គួរតែពិចារណាដាក់ចូលទាំងច្បាប់ ស្តីពីប៉ូលីស និងច្បាប់ស្តីពីពន្ធនាគារ
- ត្រូវទាក់ទងទៅនឹងនីតិវិធីតុលាការ ស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់តុលាការគំរូ ដែល ត្រូវអនុម័តដោយក្រុមការងារជាន់ខ្ពស់នៃតុលាការគំរូ
- ចំណុចទាក់ទងនឹងនីតិវិធីពាក់ព័ន្ធនឹងការបណ្តុះបណ្តាលនៃការជ្រើសរើសអ្នកបំរើក្នុងវិស័យតុលាការ ធ្វើយ៉ាងណាអោយការជ្រើសរើសមានតម្លាភាព
- ទាក់ទងជាមួយនឹងការប្រឆាំងអំពើពុករលួយ គឺធ្វើយ៉ាងណាគួរតែផ្តោតទៅលើការកសាងសមត្ថភាពមន្ត្រីដែលមានកជំនាញ និងការអនុវត្ត

លោកស្រី Momo, Jica, បានធ្វើការសង្ខេបអំពីប្រវត្តិសូចនាករតាមដានរួម ដូចខាងក្រោមនេះ ៖

- កំណត់ការធ្វើទំនើបនីយកម្មក្របខ័ណ្ឌច្បាប់ និងការកសាងសមត្ថភាពក្នុងការធ្វើច្បាប់ និង សកម្មភាពដែលចាំបាច់ត្រូវអនុម័ត
- ចំពោះសូចនាករតាមដានរួមដែលបានកំណត់ដោយក្រុមការងារបច្ចេកទេសនេះ មិនបាច់ធ្វើការកែប្រែទេ គួរតែធ្វើការអនុវត្តជាបន្ត ហើយយើងគួរតែទទួលស្គាល់ថា យើង មានការរីកចំរើនលើវិស័យនេះ គឺយើងមានការអនុម័តច្បាប់មួយចំនួនក្នុងចំណោមច្បាប់ជាមូលដ្ឋានសំខាន់ៗ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍ថា អ្វីដែលយើងត្រូវធ្វើនៅពេលខាងមុខពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ និងតុលាការ គឺជាសកម្មភាពមួយដែលយើងត្រូវអនុវត្ត ដើម្បីសម្រេចនូវគោលដៅ គឺយើងមាននូវច្បាប់ជាមូលដ្ឋានមួយចំនួនហើយ និងច្បាប់ខ្លះទៀតមិនទាន់បានអនុម័តនៅឡើយ ហើយយើងបានឈានទៅដល់ការអនុវត្តនូវច្បាប់ជាមូលដ្ឋាន ។

លោកស្រី Momo លោកស្រីទើបនឹងទទួលបានឯកសារថ្ងៃនេះ យើងមិនទាន់ពេលវេលាគ្រប់គ្រាន់ដើម្បីលើកជាសំណូមពរឡើង ដូច្នេះយើងកំណត់ ( IMS ) លើកមុនយើងបានបង្កើនជាក្រុម គឺក្រុមម្ចាស់ជំនួយមួយក្រុម និងក្រុមខាងរដ្ឋាភិបាលបានជួបជុំគ្នាមួយក្រុម ហើយយើងពិភាក្សាលើកជាមតិយោបល់ផ្សេងៗ ដើម្បីកំណត់ ( IMS ) នេះ ។

លោកស្រីក៏បានលើកដែរថា នេះជាសំណូមពរដោយសូមអោយដៃគូអភិវឌ្ឍន៍ និងប្រទេសអ្នកផ្តល់ជំនួយ ជួបជុំពិភាក្សាគ្នាមួយក្រុម និងមួយក្រុមទៀតខាងរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដែលអាចមានមតិយោបល់ ប្រហាក់ប្រហែលគ្នា ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍ថា ដូចដែល លោកស្រី Momo បានលើកឡើងពី ( IMS ) ចាស់ ដែលយើងបានបង្កើតជាពីរក្រុមដើម្បីទទួលមតិយោបល់ផ្សេងៗគ្នា ហើយឯកឧត្តមបានស្នើសុំ ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលមេត្តាចូលរួមផ្តល់ជាមតិយោបល់ផ្សេងៗ និងម្ខាងទៀតរវាងដៃគូអភិវឌ្ឍន៍ និង ប្រទេសអ្នកផ្តល់ជំនួយ ក្នុងការដាក់បញ្ចូលប្រព័ន្ធសូចនាករតាមដានថ្មីនេះ ។ ជាមួយគ្នានោះដែរ ឯកឧត្តម បានជម្រាបជូនអង្គប្រជុំពីការធ្វើសិក្ខា សាលាមួយស្តីពីកម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់លើសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលសិក្ខាសាលានៅ សណ្ឋាគារសាន់វ៉េ កាលពីថ្ងៃទី ២៦-០៣-២០០៨ ដែលរៀបចំដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងអង្គភាពគ្រប់គ្រងគម្រោងដើម្បីប្រមូលព័ត៌មាន និងអនុសាសន៍ទាំងឡាយដាក់ជូនទៅក្រុមប្រឹក្សា ។

ទីបញ្ចប់ ឯកឧត្តម សំ សុខផល បានថ្លែងអំណរគុណចំពោះការចូលរួមពិគ្រោះយោបល់ក្នុងអង្គប្រជុំទាំងមូល និងសម្រេចថានឹងបន្តកិច្ចប្រជុំលើកទី៣ ធ្វើនៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ ខាងមុខនេះ ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងប្រាំល្ងាចនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៨*

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង　　　　　　អ្នកធ្វើរបាយការណ៍

ស៊ុយ ម៉ុងលាង　　　　　　សេង វ៉ាន់ដា　　　ស៊ុន សិរីរុធ

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
នាថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨

០១-ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ
០២-ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៣-ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៤- ឯកឧត្តម ទេព ដ៉ារុង ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
០៥-លោកជំទាវ សម មូនីកា អគ្គនាយករងក្រសួងកិច្ចការនារី
០៦-ឯកឧត្តម ផៃ សុខខេង ប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ ក.ក.ច.ន.យ
០៧-លោក ជឹង ផេងស្រ៊ួយ ប្រធានក្រុមគម្រោងបណ្ណសារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ
០៨-កញ្ញា ផាន់ ពីសីនលក្ខណ៍ មន្ត្រី ក.ក.ច.ន.យ
០៩-លោក Ben Schultz, Adviser (CCJAP III)
១០-លោកស្រី ឈូក សារ៉ុម មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ

១១-លោក ស៊ុន សិរីវុធ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ

១២-លោក ជ សៀកវែង CCJAPIII

១៣-លោក ឃ្លោក ដារ៉ា ប្រធាន ក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

១៤-លោកស្រី ស្រី ប៊ុណ្ណាវ័ត្ន អនុប្រធានក្រុមគម្រោងបណ្ណសារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ

១៥-លោក ផៃ លី អនុប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ ក.ក.ច.ន.យ

១៦- Kheang Seng, AGU

១៧- Momoko Hotta (Assistant Resident Representative, JICA )

១៨- Mr. Rajan Shah (Access to Justice Advisor) EWMI

១៩- Kana Manabe (Legal Advisor) MOJ/JICA

២០- Lesley Miller ( UNICEF Chief Child Protection )

២១- Izumi Mochizuki, Japenese Embassy

២២- Filipi Christiane, French Cooperation

២៣- Mr. Ly Tay Seng (Secretary General ) "

២៤- Hermoso Elise (Assistant), French Cooperation

២៥- Katharina Huebnes, GTZ

២៦- ហ៊ាង សុខឃៀង មន្ត្រី (ACU)

២៧- Katherine Mitchell(Second Sectetary), AusAid

២៨- Sun Samnang(Legal Officer), EWMI

២៩- សូរ ឌីម៉ា ក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ